ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមេសា និងទិសដៅការងារខែឧសភា ឆ្នាំ២០១៦

**សេចក្តីផ្តើម :**

នៅក្នុងខែមេសានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោមនេះ៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:

### ១.មុខងារនីតិកម្ម:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក ដើម្បីប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី និងពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីសហជីព<br>- ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីសហជីព ។ | - រៀបចំទីកន្លែង ចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គព្រឹទ្ធសភា និងប្រជុំគណៈកម្មការជំនាញចំនួន០៤លើក<br>- បានផ្គត់ផ្គង់សម្ភារៈ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គ និងប្រជុំគណៈកម្មការផ្សេងៗសរុបចំនួន០៤សំណើ មានអ្នកចូលរួមចំនួន១៣១នាក់<br>- ថតចម្លងឯកសារបានចំនួន០៤សំណើ អស់ក្រដាសចំនួន៧,២៩៦សន្លឹក និងធ្វើជាសៀវភៅចំនួន៣៥ក្បាល អស់ក្រដាសចំនួន៥,៦៣៥សន្លឹក<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកម្មវិធីផ្សេងៗ |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

| | |
|---|---|
| | ចំនួន៥២នាក់ ស្មើនឹង០៣លើក និងកម្លាំងអន្តរាគមន៍ពីស្ថាប័នខាងក្រៅមានចំនួន៦៣នាក់<br>- បានធ្វើសេចក្តីសម្រេច ស្តីពីការប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី និងសេចក្តីសម្រេចស្តីពីការចាត់តាំង និងកែសម្រួលសមាសភាពក្រុមសមាជិកសមាជិកាព្រឹទ្ធសភាប្រចាំភូមិភាគ<br>- ប្រជុំក្រុមការងារបច្ចេកទេស ដើម្បីពិនិត្យសិក្សាស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងសេចក្តីស្នើបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងសិក្សាស្រាវជ្រាវរៀបចំសេចក្តីព្រាងក្រមសីលធម៌សមាជិកព្រឹទ្ធសភា<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់ពីរាជរដ្ឋាភិបាល និងបានចាត់ចែងតាមនីតិវិធី<br>- បន្តធ្វើបច្ចុប្បន្នភាពបញ្ជីច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់តាមឆ្នាំ និងនីតិកាល<br>- បាននឹងកំពុងបន្តសិក្សាស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីសេចក្តីព្រាងច្បាប់ចំនួន០៣ និងស្រាវជ្រាវលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងតម្រូវការចាំបាច់របស់ស្ថាប័នចំនួន០៧<br>- បន្តធ្វើការចងក្រងឯកសារព័ត៌មានបរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធប្រចាំខែមេសា និងខែមិថុនា ឆ្នាំ២០១៦ មានចំនួន០៥ច្បាប់<br>- បានផ្សព្វផ្សាយសេចក្តីជូនដំណឹង សេចក្តីប្រកាសព័ត៌មាន តាមFacebook សារព័ត៌មាន និងស្ថានីយទូរទស្សន៍ចំនួន០៦លើក ថតសម្លេង និងថតកាម៉េរ៉ាវីដេអូចំនួន២០លើក បង្ហោះលើគេហទំព័រព្រឹទ្ធសភា និងផលិតជា Video Online ចំនួន១២លើក។ |

២.មុខងារតំណាង :

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបានៈ<br>- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីថ្វាយព្រះពរសព្រ្វាន្តឆ្នាំថ្មីថ្វាយព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា<br>- អញ្ជើញជាអធិបតីក្នុងពិធីបង្សុកូល ឧទ្ទិសកុសលជូនសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម និងលោកជំទាវ នៅខេត្តព្រៃវែង និងជូនបុព្វការីជនញាតិការទាំងប្រាំពីរសណ្តាន នៅខេត្តកំពង់ចាម<br>- អញ្ជើញជាអធិបតីក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូនសមាជិក សមាជិកា និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- អញ្ជើញចុះជួបសំណេះសំណាលជាមួយមហាជន និងជាអធិបតីក្នុងពិធីសម្ពោធ និងឆ្លងសមិទ្ធផលនានា ព្រមទាំងបានពិនិត្យទ្វារទឹក០២កន្លែង និងប្រឡាយមួយខ្សែប្រវែង៤,១៥០ម៉ែត្រ និងឧបត្ថម្ភថវិកាចំនួន១២,៧៥៨ដុល្លារសហរដ្ឋអាមេរិក សម្រាប់ការជួសជុលស្តារ និងពង្រីកប្រឡាយខាងលើនេះ នៅខេត្តកំពង់ស្ពឺ | - រៀបចំពិធីជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន និងជាអធិបតីភាព ក្នុងពិធីផ្សេងៗចំនួន១៥លើក<br>- បានអមដំណើរសមាជិកព្រឹទ្ធសភា ចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយជូនកងទ័ពវរៈសេនាតូចការងារព្រំដែនលេខ៥០៨ ចំនួន២១០នាក់ ឈរជើងនៅឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់<br>- រៀបចំពិធីបំពាក់គ្រឿងឥស្សរិយយស ជូនសមាជិក សមាជិកា និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានធ្វើកំណត់បង្ហាញ បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន១៦ករណី<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងដំណើរការរៀបចំកិច្ចប្រជុំ ការចុះស្រាវជ្រាវប្រមូលព័ត៌មាន ពិភាក្សាការងារ ការរៀបចំវេទិកា ការចុះតាមដានស្វែងយល់លទ្ធផលក្រោយការរៀបចំវេទិកា និងកម្មវិធីផ្សេងៗ<br>- បានធ្វើរបាយការណ៍ផ្សព្វផ្សាយព័ត៌មាន ស្តីពីការងាររបស់សមាជិកគណៈកម្មការចំនួន១៨លើក<br>- បានធ្វើបច្ចុប្បន្នភាពក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ (ខេត្តតាកែវ កំពត កែប កំពង់ចាម ត្បូងឃ្មុំ បាត់ដំបង និងខេត្តព្រះសីហនុ)<br>- បានរៀបចំទីកន្លែងសម្រាប់កិច្ចប្រជុំ សិក្ខាសាលា បទបង្ហាញ ពិធីចុះហត្ថលេខា ពិធីសូត្រមន្តចូល |

- អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខអាជ្ញាធរ ប្រជាពលរដ្ឋ នៅខណ្ឌច្បារអំពៅ ខណ្ឌចំការមន ខណ្ឌទួលគោក និងអញ្ជើញនាំបច្ច័យសម្រាប់ការកសាងសមិទ្ធផលក្នុងវត្តចំនួន៨០លានរៀល នៅវត្តជេតពនរាជធានីភ្នំពេញ
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយសហជីព កម្មករនិយោជិត និងតំណាងមន្ត្រីរាជការគ្រូបង្រៀន ដើម្បីអបអរសាទរបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ និងទិវាពលកម្មអន្តរជាតិ ០១ឧសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសាលមហោស្រពកោះពេជ្រ
- អញ្ជើញចូលរួមអបអរសាទរពិធីប្រគល់ពានរង្វាន់សន្តិភាព និងការអភិវឌ្ឍជូនសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា
- អញ្ជើញជាអធិបតីថ្លែងសុន្ទរកថាបើកវេទិកាភូមិភាគ១ នៅព្រឹទ្ធសភា
- អញ្ជើញជាអធិបតីក្នុងពិធីប្រគេនភ្លើងបូជាព្រះសព ព្រះព្រហ្មធម្ម **ស៊ីវ គីមសន** ព្រះរាជាគណៈថ្នាក់កិត្តិយស និងជាទីប្រឹក្សាផ្ទាល់សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** នៅវត្តម្រំ

ឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងកិច្ចពិភាក្សាផ្សេងៗ ចំនួន១០លើក

- សហការរៀបចំទីកន្លែងសម្រាប់វេទិកាចំនួន០១លើក នៅព្រឹទ្ធសភា មានអ្នកចូលរួមសរុបចំនួន៣២៨នាក់
- ផ្ញើលិខិតបេសកកម្មជូនសមាជិក សមាជិកា និងមន្ត្រីរាជការព្រឹទ្ធសភាចំនួន១០៥នាក់ ស្មើនឹង២៥ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០៩នាក់ ស្មើនឹង០៩ច្បាប់
- ថតចម្លងឯកសារចំនួន១៦សំណើ អស់ក្រដាសចំនួន២៥,០៣៥សន្លឹក និងធ្វើជាសៀវភៅចំនួន៤៥ក្បាល អស់ក្រដាសចំនួន៧,១៥៥សន្លឹក ព្រមទាំងផ្តល់សេវាដឹកជញ្ជូនក្នុងរាជធានីចំនួន២៧លើក
- ទទួលលិខិតចូលចំនួន៦៣០ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៥៥៥ច្បាប់
- ផ្សព្វផ្សាយសារជូនពរ ប័ណ្ណជូនពរ ចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរចំនួន៥៦០០សន្លឹក និងផលិតព្រឹត្តិបត្រព្រឹទ្ធសភា ប្រចាំខែមីនា ឆ្នាំ២០១៦ ចំនួន២៥០០ក្បាល
- បានរៀបចំពិព័រណ៍រូបភាពចំនួន៥៥សន្លឹក នៅមុខអគារក្រហម និងខាងមុខក្លោងទ្វារធំព្រឹទ្ធសភា
- ផ្តល់សៀវភៅជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈចំនួន៧០ក្បាល
- ផ្តល់រូបថតចំនួន៥២០សន្លឹក និងឯកសារព្រឹត្តិបត្រ-អត្ថបទសារព័ត៌មានចំនួន៣៧អត្ថបទ
- ទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១៩៥នាក់ ធ្វើប័ណ្ណសមាជិក ០៨នាក់ ខ្ចីសៀវភៅចំនួន៤២ក្បាល និងសងវិញ

| | |
|---|---|
| ខាងជើង ខេត្តកំពង់ស្ពឺ និងនាំយកទេយ្យទានទៅប្រគេនព្រះសង្ឃ និងចែកអំណោយជូនប្រជាពលរដ្ឋក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ នៅខេត្តតាកែវ និងខេត្តពោធិ៍សាត់<br>- អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធជាផ្លូវការគោជនីយដ្ឋាន បុងជូ ខេមបូឌា នៅរាជធានីភ្នំពេញ<br>- អញ្ជើញចូលរួមសម្ពោធសមិទ្ធផល និងដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមនុស្សធម៌មកពីប្រទេសបារាំង ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តកណ្តាល និងខេត្តស្ទឹងត្រែង<br>- អញ្ជើញចុះជួបសំណេះសំណាល ជាមួយប្រជាពលរដ្ឋ នៅខេត្តព្រៃវែង និងខេត្តពោធិ៍សាត់<br>- បានធ្វើបទបង្ហាញស្តីពីតួនាទី ភារកិច្ច របស់ព្រឹទ្ធសភា និងដំណើរការនីតិកម្ម របស់ព្រឹទ្ធសភា<br>- បានប្រជុំជាមួយអាជ្ញាធរខេត្ត ដើម្បីពិភាក្សាអំពីការត្រៀមរៀបចំវេទិកាថ្នាក់ខេត្ត នៅខេត្តកំពត និងខេត្តបន្ទាយមានជ័យ<br>- អញ្ជើញចូលរួមធ្វើបទឧទ្ទេសនាមស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធព្រឹទ្ធសភា នៅបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | ចំនួន៤៤ក្បាល<br>- សម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សាចំនួន ០៣លើក របស់លោកគ្រូ អ្នកគ្រូមកពីវិទ្យាល័យ អ៊ីជិយីគិ ខេត្តកំពង់ស្ពឺ ចំនួន៥០នាក់ វិទ្យាល័យ ជា ស៊ីម ខេត្តព្រៃវែង ចំនួន៣៣នាក់ និងសិស្សវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន ព្រែកថ្មីចំនួន៣៥នាក់<br>- ទទួលឯកសារសៀវភៅពីអង្គការ ស្ថានទូត ស្ថាប័ន ក្រសួង គ្រឹះស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន ១៣៦ក្បាល ព្រឹត្តិបត្រ ចំនួន ៣៣ក្បាល ទស្សនាវដ្តី ចំនួន៥៩ក្បាល និងរាជកិច្ចចំនួន៤១ក្បាល<br>- ផ្តល់សៀវភៅ និងឯកសារផ្សេងៗរបស់ព្រឹទ្ធសភា ជូនសាកលវិទ្យាល័យនានា ចំនួន៣៤៩ក្បាល<br>- រៀបចំសៀវភៅច្បាប់ កាសែត ទស្សនាវដ្តី រាជកិច្ច ចំនួន២៨២ក្បាល និងដាក់លេខកូដសៀវភៅថ្មីចំនួន ១៣៥ក្បាល ។ |

| | |
|---|---|
| - ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានរៀបចំវេទិកា ស្តីពីការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ផ្តោតលើប្រធានបទ "ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ការអភិវឌ្ឍស្រុក-ខណ្ឌ និងភូមិ-សង្កាត់មានសុវត្ថិភាព" នៅព្រឹទ្ធសភា<br>- ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន ១៣ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន១៦ករណី កំណត់បង្ហាញពាក្យបណ្តឹងបានចំនួន១៧ករណី ទទួលពាក្យបណ្តឹងជូនជ្រាបចំនួន០២ករណី និងតម្កល់ទុកមិនចាត់ការចំនួន០២ករណី<br>- ព្រឹទ្ធសភាបានទទួលលិខិតពីរដ្ឋសភាចំនួន១៣៨ច្បាប់ ព្រមទាំងទទួលឯកសារពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលមាននាមរបស់សមាជិកព្រឹទ្ធសភាចំនួន ២១៩ច្បាប់ និងថ្នាក់ដឹកនាំបានចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន ១០៩ច្បាប់ ។ | |

៣.**មុខងារតាមដានការអនុវត្តច្បាប់/មុខងារព័ត៌មាន**:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភាបាន៖<br>+ អញ្ជើញចុះទៅតាមដានការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការផ្សព្វផ្សាយព័ត៌មាន វឌ្ឍនភាពសំខាន់ៗ និងបញ្ហា | - ធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភាចំនួន ចំនួន៥៦នាក់ ស្មើនឹង០៦ច្បាប់ និងជូនមន្ត្រីរាជការអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅសិក្សាស្វែងយល់អំពីការអនុវត្តច្បាប់ចំនួន៤៧នាក់ |

| | |
|---|---|
| ប្រឈមនានា នៅខេត្តបាត់ដំបង ប៉ៃលិន មណ្ឌលគិរី រតនគិរី និងខេត្តស្ទឹងត្រែង ដែលមានសមាជិកចូលរួមចំនួន០៩រូប<br>+ អញ្ជើញចុះបេសកកម្ម ដើម្បីសិក្សាស្វែងយល់អំពីការអនុវត្តសិទ្ធិមនុស្ស និងការដោះស្រាយពាក្យបណ្តឹងរបស់ថ្នាក់ក្រោមជាតិ នៅខេត្តស្វាយរៀង និងខេត្តត្បូងឃ្មុំ ។ | ស្មើនឹង០៨ច្បាប់<br>- បានតាមដានព័ត៌មាន សិក្សាស្រាវជ្រាវ និងធ្វើតារាងសង្ខេបស្តីពីវឌ្ឍភាពការងាររបស់ក្រសួងស្ថាប័ននានាចំនួន០២ច្បាប់<br>- ផ្តល់សេវាដឹកជញ្ជូន ចំនួន៥៦នាក់ ស្មើនឹង១០លើក<br>- ថតចម្លងឯកសារបានចំនួន០១សំណើ អស់ក្រដាសចំនួន២០០សន្លឹក ។ |

## ៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា អនុញ្ញាតឲ្យគណៈប្រតិភូសាធារណរដ្ឋប្រជាមានិតចិន ចូលជួបសម្តែងការគួរសម និងសវនាការ និងអនុញ្ញាតឲ្យភ្ញៀវជាតិអន្តរជាតិចូលជួបជូនពរក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ<br>- ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា ជួបពិភាក្សាការងារ ជាមួយនាយកប្រតិបត្តិនៃវិទ្យាស្ថានសន្ទនាមេគង្គ (MDI) និងសហការី ព្រមទាំងអគ្គរដ្ឋទូតតួកគី<br>- សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញទៅទស្សនកិច្ចនៅរដ្ឋសភានៃសាធារណរដ្ឋបារាំង ចូលរួមកិច្ចប្រជុំគណៈកម្មការនយោបាយ នៃសភាប្រើប្រាស់ភាសាបារាំង (APF) នៅសហរដ្ឋអាមេរិក ចូលរួមកិច្ចប្រជុំគណៈកម្មាធិការ | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អគ្គទូត និងអង្គការអន្តរជាតិនានា<br>- ថតសំលេងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជួបភ្ញៀវ កិច្ចប្រជុំ សិក្ខាសាលា និងក្នុងកម្មវិធីផ្សេងៗ ចំនួន៣៦លើក<br>- បានយកព័ត៌មាន ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ជួបភ្ញៀវជាតិ-អន្តរជាតិចំនួន២៣លើក<br>- រៀបចំតុបតែងលម្អទីកន្លែង ទង់ជាតិ វត្ថុអនុស្សាវរីយ៍ ចាត់ចែងអ្នកបកប្រែប្រព័ន្ធផ្សព្វផ្សាយ<br>- រៀបចំសម្អាតសាល ផ្គត់ផ្គង់គេសជ្ជៈ សម្ភារអនាម័យក្នុងពិធីផ្សេងៗចំនួន១០លើក<br>- ទំនាក់ទំនងជាមួយស្ថានទូតបណ្តាប្រទេសជាមិត្ត ដើម្បីសម្រួលបែបបទ និងកម្មវិធីទស្សនកិច្ច ធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូត |

| | |
|---|---|
| អចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការសង្គម និងវប្បធម៌របស់សភាតំបន់អាស៊ី នៅសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ និងកិច្ចប្រជុំស្តីពីភាពជាដៃគូសភាអាស៊ី-អឺរ៉ុបលើកទី៩ នៅប្រទេសម៉ុងហ្គោលី ចូលរួមទស្សនកិច្ចសន្ទនាស្វែងយល់ពីការអភិវឌ្ឍស្ថានភាពសិទ្ធិមនុស្ស នៅប្រទេសស៊ុយអែត ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់រង្វាន់ជូនដល់សហគ្រិនស្មោះត្រង់អាស៊ី-ប៉ាស៊ីហ្វិកលើកទី១៤ នៅប្រទេសម៉ាឡេស៊ី និងទស្សកិច្ចសិក្សាជួបពិភាក្សាការងារ និងផ្លាស់ប្តូរបទពិសោធន៍ការងារ នៅប្រទេសឥណ្ឌា និងសាធារណរដ្ឋកូរ៉េ ។ | និងជំនួយស្មារតី រៀបចំបែបបទបើកបន្ទប់ពិសេស (VIP) នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជូន-ទទួលដំណើរបេសកកម្មសរុបចំនួន៤២លើក<br>- ចេញលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការចំនួន១៧នាក់ ស្មើនឹង០៤ច្បាប់ និងបញ្ជូនលិខិតទៅក្រៅស្ថាប័នព្រឹទ្ធសភាចំនួន៥៨ច្បាប់<br>- រៀបចំកញ្ចប់ដំណើរបេសកកម្មជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ទៅបំពេញបេសកកម្មក្រៅប្រទេសចំនួន០៨លើក<br>- ការពារសន្តិសុខ សុវត្ថិភាព រៀបចំសណ្តាប់ធ្នាប់ជូនថ្នាក់ដឹកនាំក្នុងកម្មវិធីផ្សេងៗ ដោយប្រើប្រាស់កម្លាំងសរុបចំនួន៦០នាក់ ស្មើនឹង០៥លើក<br>- ថតចម្លងឯកសារបានចំនួន០៣សំណើ អស់ក្រដាសចំនួន១,០១៧សន្លឹក និងធ្វើជាសៀវភៅចំនួន០៥ក្បាល អស់ក្រដាសចំនួន១,៥០០សន្លឹក ផ្តល់សេវាដឹកជញ្ជូនក្នុងរាជធានី និងតាមបណ្តាខេត្តទាំង៨ភូមិភាគចំនួន៤៩នាក់ ស្មើនឹង២២លើក<br>- អគ្គលេខាធិការ បានអញ្ជើញជាអធិបតីក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកម្មវិធីអភិវឌ្ឍន៍សមត្ថភាពដល់មន្ត្រីសភា ដែលជាសមាជិកអន្តរសភាអាស៊ាន និងពិធីចុះហត្ថលេខាសហប្រតិបត្តិការខាងការបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មានជាមួយអង្គការកូរ៉េ<br>- ទំនាក់ទំនងជាមួយសភាវ៉ាឡូនី ព្រុចសែល បែលហ្ស៊ិក អង្គការ UNESCO, KAS សាលាភូមិន្ទរដ្ឋបាល ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង សមាគមមនុស្សធម៌ |

| | |
|---|---|
| | សមាគមអគ្គលេខាធិការនិយាយភាសាបារាំង សង្គមស៊ីវិល អាកាសចរណ៍ស៊ីវិល អគ្គស្នងការនគរបាលជាតិ សាលាខេត្តព្រះសីហនុ កំពង់ផែស្វយ័ត និងក្រសួង-ស្ថាប័ននានា សម្រាប់ដំណើរទស្សនកិច្ច សិក្ខាសាលា និងបំពេញបេសកកម្មផ្សេងៗ ស្នើសុំអាហារូបករណ៍ និងវគ្គបណ្តុះបណ្តាលផ្សេងៗ ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន :**

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - ព្រឹទ្ធសភាកំពុងអនុវត្តការសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា ជាជំនួយពីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន<br>- សហប្រតិបត្តិការជាមួយដៃគូរ ដើម្បីអភិវឌ្ឍធនធានមនុស្ស និងអភិវឌ្ឍស្ថាប័ន ។ | - ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤១០ច្បាប់<br>+ការងារគ្រប់គ្រងបុគ្គលិកៈ<br>- បានធ្វើលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៤៥ច្បាប់<br>- បង្កើតគណៈកម្មការ ដើម្បីធ្វើបច្ចុប្បន្នភាពបទបញ្ជាផ្ទៃក្នុងអគ្គលេខាធិការដ្ឋាន តាមស្មារតីអនុក្រិត្យរបស់រាជរដ្ឋាភិបាល<br>- ប្រជុំស្តីពីការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា<br>- ប្រជុំស្តីពីទិសដៅការងារសម្រាប់ត្រីមាសទី២ ឆ្នាំ២០១៦<br>- ប្រជុំស្តីពីការតែងតាំងមន្ត្រីរាជការឲ្យកាន់មុខតំណែងក្នុងអង្គការលេខនៃរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំគណៈកម្មការ ដើម្បីពិនិត្យលក្ខណៈសម្បត្តិបេក្ខជនស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការដែលមានស្នាដៃសម្រាប់ឆ្នាំ២០១៥ និងប្រជុំគណៈកម្មការ |

សិក្សាកែប្រែតម្លៃសន្ទស្សន៍បៀវត្ស ពី១,៥២០រៀល ទៅ១,៧០០រៀល តាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាល

- បានកសាងសេចក្ដីព្រាងស្ដីពី គោលការណ៍តែងតាំងមន្ត្រីរាជការឲ្យកាន់មុខតំណែង

+ការងារបណ្ដុះបណ្ដាលធនធានមនុស្ស:

- ការបណ្ដុះបណ្ដាលធនធានមនុស្សនៅក្នុង-ក្រៅប្រទេសសរុបចំនួន០៥វគ្គ មានសិក្ខាកាមចូលរួមចំនួន១៤នាក់
- កសាងផែនការបណ្ដុះបណ្ដាល និងអភិវឌ្ឍន៍ធនធានមនុស្សនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភារយៈពេល០៥ឆ្នាំ (២០១៧-២០២១)

+ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

- រៀបចំកសាងយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិលព្រឹទ្ធសភា (២០១៧-២០១៩)
- រៀបចំថវិកាតាមកម្មវិធីឆ្នាំ២០១៦ និងការរៀបចំគម្រោងថវិកា ឆ្នាំ២០១៧
- រៀបចំស្នើសុំឥណទានបន្ថែមសម្រាប់ប្រាក់ឧបត្ថម្ភប្រចាំខែជូនបុគ្គលិកជាប់កិច្ចសន្យា និងតម្លៃសន្ទស្សន៍បៀវត្សពី១,៥២០រៀល ទៅ១,៧០០រៀល
- ទូទាត់ថវិកាសម្រាប់រៀបចំពិធីជប់លៀងជូនមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ និងទូទាត់ថ្លៃទិញសម្ភារគ្រឿងអេឡិចត្រូនិចចំនួន១៩លើក ថែទាំ និងជួសជុលសម្ភារឧបករណ៍បច្ចេកទេសផ្សេងៗចំនួន០៦លើក ទូទាត់ការបោះពុម្ពសៀវភៅ និងឯកសារផ្សេងៗសរុបចំនួន១,០៦០ក្បាល
- ទូទាត់ថ្លៃលទ្ធកម្មសម្ភារ ការិយាល័យ អនាម័យ

| | |
|---|---|
| | ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងមន្ត្រីមិនមែនក្របខ័ណ្ឌ របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែមេសា ឆ្នាំ២០១៦ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- រៀបចំសម្អាតសាល និងផ្តល់សេវាភេសជ្ជៈ ក្នុងពិធីផ្សេងៗចំនួន១៣លើក មានអ្នកចូលរួមចំនួន៥៣០នាក់<br>- បានផ្គត់ផ្គង់សម្ភារអនាម័យ ការិយាល័យ និងភេសជ្ជៈចំនួន៣៩សំណើ<br>- ថតចម្លងឯកសារបានចំនួន៣៩សំណើ អស់ក្រដាសចំនួន១៥,០២៨សន្លឹក និងរៀបចំចងក្រងធ្វើជាសៀវភៅចំនួន៥៦ក្បាល អស់ក្រដាសចំនួន ២,២៦០សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូនក្នុងរាជធានីចំនួន៤២នាក់ ស្មើនឹង៣៧លើក<br>+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រឹង និងទន់:<br>- កសាងគម្រោងរៀបចំបណ្ណាល័យអេឡិចត្រូនិច<br>- បន្តតាមដាន សហការ និងត្រួតពិនិត្យដំណើរការការដ្ឋានសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា<br>- រៀបចំទិន្នន័យ និងប្លង់: អគ្គិសនី លូទឹក ប្រព័ន្ធទឹកស្អាត ផ្លូវថ្នល់ ការជួសជុលកែលម្អអគារបណ្ណាល័យ និងការរៀបចំកែលម្អសួនច្បារថ្មី<br>- រៀបជញ្ជាំងថ្មក្លំនៅខាងក្រោយបណ្ណាល័យជាប់ |

របង៨៩ និងខាត់លាបស្នាមប្រឡាក់តាមជញ្ជាំង នៅសាលបណ្ណាល័យ ព្រមទាំងប្តូរពិដាន និងបិទប្រឡោះការពារ ដើម្បីកុំឲ្យសត្វប្រចៀវហើរចូលសាលពេញអង្គ

- ជួសជុល និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច សោទ្វារ អូតូទ្វារ សោគុទូ ចំនួន ៤១៤គ្រឿង/ខ្សែ បន្ទប់ទឹក និងបណ្តាញទឹកចំនួន ០៤គ្រឿង/លើក
- សហការរៀបចំ និងប្រចាំការម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំចំនួន១០លើក និងរៀបចំសណ្តាប់ធ្នាប់រថយន្តគ្រប់ប្រភេទនៅក្នុងព្រឹទ្ធសភាចំនួន៤១លើក
- រៀបចំដំណើរការប្រព័ន្ធព័ត៌មានវិទ្យា (ICT) ជាមួយក្រុមបច្ចេកទេសវៀតណាម
- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork, Internet, Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីUnicode និងSet up កម្មវិធីសរុបចំនួន ៥១គ្រឿង ។ រៀបចំមាតិកា និង Upload រូបភាពសកម្មភាពការងារសំខាន់ៗរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាសរុបចំនួន៨៥ប្រធានបទ

+ការងារផ្សេងៗ:

- ការពារសន្តិសុខ សុវត្ថិភាពជូនថ្នាក់ដឹកនាំ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៣៦នាក់
- ការរៀបចំសច្ចាប្រណិធានជូនសមាជិកព្រឹទ្ធសភា ចំនួន០២រូប ចូលកាន់តំណែងថ្មី នៅព្រះបរមរាជវាំង
- ការរៀបចំការិយាល័យធ្វើការ ឯកសណ្ឋាន សញ្ញាសក្តិជូនសមាជិកព្រឹទ្ធសភាថ្មី ចូលកាន់មុខតំណែង ។

## II.ទិសដៅការងារខែឧសភា ឆ្នាំ២០១៦

**១.មុខងារនីតិកម្ម:**

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា (វិស្សមកាលថ្ងៃ១២ ខែមេសា ឆ្នាំ២០១៦)

-សិក្សាច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា តាក់តែងក្រមសីលធម៌ និងបទបញ្ជាផ្ទៃក្នុងថ្មី។

**២.មុខងារតំណាង :**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្តាខេត្ត-ក្រុង

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ ។

**៣.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ :**

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត-ក្រុង ។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ**

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា រួមទាំងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

-បន្តសកម្មភាពសហប្រតិបត្តិការការងារជាមួយដៃគូនានា៖ SES, CIM, KAS, GIZ, MARC PLAN FOUNDATION, UNESCO និងKOICA

-បន្តសហការជាមួយវិទ្យាស្ថានសភាកម្ពុជា អំពីជំហានរៀបចំការិយាល័យ PBO និងការពង្រីកឥទ្ធិពលតំបន់របស់វិទ្យាស្ថានសភាកម្ពុជាក្នុងក្របខណ្ឌសហប្រតិបត្តិការតំបន់ (ត្បូង-ត្បូង) និងការបង្កើតវិទ្យាស្ថានស្រាវជ្រាវសភាអាស៊ាន ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន :**

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវអំពីឯកសារបច្ចុប្បន្នភាពរបស់ជាតិ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ តាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាល ក្នុងនោះចូលអនុវត្តកម្មវិធី E-បណ្ណាល័យ

-បន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន កិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ជប៉ុន ឥណ្ឌា និងការបំពាក់សម្ភារបរិក្ខារជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម

-បន្តកសាងគោលការណ៍ គោលនយោបាយថ្មី ដើម្បីជាផលប្រយោជន៍ដល់ស្ថាប័ន និងមន្ត្រីរាជការ

-បន្តកសាងគោលការណ៍ណែនាំអំពីការរៀបចំដំណើរទស្សនកិច្ចសិក្សា និងកសាងខ្សែវីដេអូឯកសារ និងបោះពុម្ពឯកសារផ្សេងៗ

-ចាត់ចែងដំណើរការអង្គភាពនៃសវនកម្មបឋម អង្គភាពផលិតវីដេអូ អង្គភាពផលិតឯកសារផ្សព្វផ្សាយ

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍តាមប្រកពតីកូរ៉េ ជប៉ុន អូស្ត្រាលី នូវែលសេឡង់ ឥណ្ឌា សិង្ហបុរី ម៉ាឡេស៊ី និងថៃ

-ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តដាក់ស្តែង

-ការរៀបចំថវិកាកម្មវិធីឆ្នាំ២០១៦ តាមអង្គភាពថវិកា និងចាប់ផ្តើមអនុវត្តការកត់ត្រាការចំណាយតាមអង្គភាពថវិកានីមួយៗ

-ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងការរៀបចំគម្រោងថវិកាឆ្នាំ២០១៧ ។

## III.សេចក្តីសន្និដ្ឋាន

ក្នុងខែមេសានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំពិធីសូត្រមន្ត និងជប់លៀងអបអរសាទរបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ និងបានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម បានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក ព្រមទាំងផ្តល់សេវាលើមុខងារផ្សេងៗទៀតជូនថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភាបានដោយរលូន ។ ដោយឡែកលើមុខងារតំណាង មានការចុះជួបប្រជាពលរដ្ឋនៅខេត្តព្រៃវែង ខេត្តពោធិ៍សាត់ និងត្រៀមរៀបចំវេទិកានៅខេត្តកំពត ព្រមទាំងការចូលរួមចុះសួរសុខទុក្ខម្ចាស់ឆ្នោតនៅតាមខេត្តនានា ។ ការអភិវឌ្ឍស្ថាប័ន បានបើកទំព័រថ្មីតាមការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។ លើការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ មានថាមពលកាន់តែមមាញឹក ហើយមានលទ្ធផលល្អប្រសើរជាបន្តបន្ទាប់ ។/.

ភ្នំពេញ,ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦

**អគ្គលេខាធិការ**

 អ៊ុំ សារឹទ្ធ